នស/រកត/០៩០៧/៣៩៣

# ព្រះរាជក្រឹត្យ

## ស្តីពីការកែសម្រួលព្រះរាជក្រឹត្យ
## លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២
## ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពីរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រាមួយ :**

ត្រូវបានកែសំរួលមុខងារ ភារកិច្ច រចនាសម្ព័ន្ធ និងកិច្ចដំណើរការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ មានខ្លឹមសារដូចខាងក្រោម ÷

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Downloaded from http://www.khmerlaws.com

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១:**

*«ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ»* ហៅកាត់ថា *«កបស»* គឺជាស្ថាប័នខួរក្បាលខាងគោលនយោបាយ សង្គម- សេដ្ឋកិច្ច សម្រាប់ប្រមុខរាជរដ្ឋាភិបាល នៅអមទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ២
## មុខងារ និង ភារកិច្ច

**មាត្រា ២:**

*កបស* មានមុខងារ និង ភារកិច្ច ដូចតទៅ ÷

- ពិនិត្យ និងរៀបចំឯកសារវិភាគ ស្រាវជ្រាវ និងសុន្ទរកថាសំខាន់ៗ ព្រមទាំងលើកឡើងនូវគំនិតផ្តួចផ្តើមទាំងឡាយ ដែលមានចរិតជាចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រកែទម្រង់ និងអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ច ជូនប្រមុខរាជរដ្ឋាភិបាល
- រៀបចំអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល សំដៅធានាឱ្យបាននូវគុណភាព និងសង្គតិភាពនៃគោលនយោបាយអភិវឌ្ឍសង្គម- សេដ្ឋកិច្ច នៅក្នុង និងរវាងវិស័យនានា និងផ្តល់យោបល់ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់ចេញនូវទិសដៅច្បាស់លាស់ សម្រាប់អនុវត្តឱ្យបានរលូននូវគោលនយោបាយ និងយុទ្ធសាស្ត្រ ផែនការប្រចាំឆ្នាំ និង កម្មវិធីវិនិយោគសាធារណៈ
- ស្នើឡើងនូវវិធានការជាក់ស្តែងនានា ក្នុងទិសដៅកែលំអការគ្រប់គ្រងសង្គម- សេដ្ឋកិច្ច និងពង្រឹងអភិបាលកិច្ច ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាន និងបូកសរុបរបាយការណ៍នានាដែលពាក់ព័ន្ធនឹងការអនុវត្តផែនការប្រចាំឆ្នាំ និងកម្មវិធីអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ព្រមទាំងផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីតម្រង់ទិស និងបង្កើនល្បឿនអនុវត្តផែនការ និងកម្មវិធីទាំងនោះ
- ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាន និងបូកសរុបការអនុវត្តការងារកែទម្រង់ និងគំនិតផ្តួចផ្តើមនានា ក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញដោយផ្ទាល់
- បូកសរុប និងធ្វើរបាយការណ៍សង្ខេប ជូនប្រមុខរាជរដ្ឋាភិបាលជ្រាប អំពីស្ថានការណ៍សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ ហើយផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដំណើរការនយោបាយសេដ្ឋកិច្ចជាតិ ឱ្យស្របទៅតាមនិន្នាការវិវត្តន៍នៃសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ

Downloaded from http://www.khmerlaws.com

- បំពេញការងារផ្សេងទៀត តាមការបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ។

## ជំពូកទី ៣

## សមាសភាព និង រចនាសម្ព័ន្ធចាត់តាំងនៃ កបស

**មាត្រា ៣:**

***កបស*** មានសមាសភាព និង រចនាសម្ព័ន្ធចាត់តាំង ដូចខាងក្រោម ÷

- ***កបស*** មានសមាជិកយ៉ាងតិចប្រាំបួនរូប ដែលត្រូវមានគុណសម្បត្តិ ចំណេះវិជ្ជា និង បទពិសោធន៍ការងារក្នុងវិស័យណាមួយនៃមុខជំនាញសំខាន់ៗដូចជា សេដ្ឋកិច្ច ហិរញ្ញវត្ថុ នីតិសាស្ត្រ ពាណិជ្ជកម្ម កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ឬ ឧស្សាហកម្ម
- ***កបស*** ត្រូវបានដឹកនាំ និង គ្រប់គ្រង ដោយប្រធាន និង មានអនុប្រធានមួយចំនួនជាជំនួយការតាមសេចក្តីត្រូវការចាំបាច់
- ប្រធាន និងអនុប្រធាន ***កបស*** អាចមានជំនួយការអមមួយចំនួនតាមតម្រូវការចាំបាច់ជាក់ស្តែង
- សមាជិក ***កបស*** នីមួយៗ អាចមានជំនួយការអមមិនលើសពីពីររូប ដែលត្រូវមានសមត្ថភាពខាងផ្នែកចំណេះដឹងយ៉ាងតិចចាប់ពីថ្នាក់បរិញ្ញាបត្រឡើង
- ប្រធាន ***កបស*** មានឋានៈស្មើទេសរដ្ឋមន្ត្រី
- អនុប្រធាន ***កបស*** មានឋានៈស្មើរដ្ឋមន្ត្រី
- សមាជិក ***កបស*** អាចមានឋានៈស្មើរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ
- ជំនួយការអមប្រធាន អនុប្រធាន និង សមាជិក ***កបស*** អាចមានឋានៈស្មើអគ្គនាយក ឬ អគ្គនាយករង ឬ ប្រធាននាយកដ្ឋាន ។

**មាត្រា ៤:**

***កបស*** មានប្រធានកិត្តិយសមួយរូប ដែលត្រូវបានជ្រើសរើសឡើងពីក្នុងចំណោមឥស្សរជន ដែលមានគុណសម្បត្តិ ក្នុងការបម្រើប្រទេសជាតិ មានបទពិសោធន៍ខ្ពស់ និង មានការទទួលស្គាល់ក្នុងមជ្ឈដ្ឋានជាតិ និង នៅលើឆាកអន្តរជាតិ ។ ប្រធានកិត្តិយស ***កបស*** មានឋានៈស្មើទេសរដ្ឋមន្ត្រី ។

**មាត្រា ៥:**

***កបស*** អាចមានទីប្រឹក្សាកិត្តិយសមួយចំនួន ដែលត្រូវបានជ្រើសរើសឡើងពីក្នុងចំណោមឥស្សរជនជាតិខ្មែរ ឬ បរទេស ដែលមានគុណសម្បត្តិក្នុងការបម្រើផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា មានបទពិសោធន៍ខ្ពស់ និង មានការទទួលស្គាល់នៅក្នុងមជ្ឈដ្ឋានជាតិ និង នៅលើឆាកអន្តរជាតិ ។

***កបស*** អាចមានអ្នកជំនាញការជាតិ និង អន្តរជាតិមួយចំនួនដែលមានសមត្ថភាពជំនាញ និង បទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

Downloaded from http://www.khmerlaws.com

**មាត្រា ៦:**

***កបស*** មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ សម្រាប់គាំទ្រកិច្ចដំណើរការការងាររបស់ខ្លួន ។

អគ្គលេខាធិការដ្ឋាន ***កបស*** ជាស្ថាប័នប្រតិបត្តិដែលដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូបមានឋានៈស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមួយចំនួនជាជំនួយការដែលអាចមានឋានៈស្មើអនុរដ្ឋលេខាធិការ ឬ អគ្គនាយក ។

មន្ត្រីបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ***កបស*** គឺជាមន្ត្រីរាជការ នៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ។

ក្នុងករណីចាំបាច់ ***កបស*** អាចមានអ្នកជំនាញ ឬ បុគ្គលិកជាប់កិច្ចសន្យាដើម្បីបំពេញការងារនៅក្នុងអគ្គលេខាធិការដ្ឋានរបស់ខ្លួន ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន ***កបស*** ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៤
## កិច្ចដំណើរការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

**មាត្រា ៧:**

***កបស*** បើកការប្រជុំរបស់ខ្លួនទៅតាមតម្រូវការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន ឬ តាមសេចក្តីបង្គាប់របស់ប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៨:**

ដើម្បីអាចបំពេញការងាររបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២ ខាងលើ ជូនប្រមុខរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ ***កបស*** ត្រូវមានតំណាងចូលរួមតាមដាន និងផ្តល់យោបល់ នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី និងអង្គប្រជុំអន្តរក្រសួងផ្សេងៗ ដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និងដោយក្រសួង- ស្ថាប័ននានា ក្នុងទិសដៅធានាសង្គតិភាព និងភាពរលូន ក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការកែទម្រង់នានារបស់រាជរដ្ឋាភិបាល ។

គ្រប់ក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល មានភារកិច្ចផ្តល់ឯកសារព័ត៌មាន និងកិច្ចសហការចាំបាច់នានាជូនដល់ ***កបស*** ។

***កបស*** មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់នៃក្រសួង- ស្ថាប័ននានានៃរាជរដ្ឋាភិបាល ឬ ឥស្សរជនដែលមានបទពិសោធន៍ និងសមត្ថភាពខ្ពស់ ដើម្បីមកចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន ។

**មាត្រា ៩:**

***កបស*** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន នៅក្នុងការបំពេញការងារ ។




Downloaded from http://www.khmerlaws.com

## ជំពូកទី ៥

## ប្រភពធនធាន

**មាត្រា ១០:**

***កបស*** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

***កបស*** មានសិទ្ធិទទួល និង គ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និង ពីប្រភពផ្សេងទៀត សម្រាប់ចំណាយលើការសិក្សាស្រាវជ្រាវ សេវារដ្ឋបាល និងសម្រាប់បម្រើសេចក្តីត្រូវការក្នុងការផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និងការឧបត្ថម្ភផ្សេងៗ តាមការចាំបាច់ក្នុងគោលដៅធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។

**មាត្រាពីរ:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រាបី:**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រាបួន:**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៧០៨.៤១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជាសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ:៣៩៧ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី... ខែកញ្ញា ឆ្នាំ២០០៧
...ទីស្តីការគណៈរដ្ឋមន្ត្រី...
ជិនកេន



Downloaded from http://www.khmerlaws.com